សួស្តី នៅក្នុងរូបភាពនេះគឺនិយាយអំពីកាត់សក់។ ដែលនៅក្នុងរូបភាពទី ១ យើងឃើញមានស្ត្រីម្នាក់
ដែលគាត់ពាក់អាវពណ៌បៃតងដៃខ្លី យើងមើលសក់របស់គាត់វែង
ដូច្នេះគាត់ក៏នឹកឃើញចង់កាត់សក់របស់គាត់ឲ្យខ្លី ដើម្បីប្តូរម៉ូត ឬក៏ដើម្បីឲ្យប្លែកមុខ។
ពីព្រោះពេលខ្លះ នៅពេលដែលយើងកាត់សក់ ឬក៏ប្តូរម៉ូតសក់របស់យើង
ធ្វើឲ្យមុខរបស់យើងប្លែកខុសពី ធ្វើឲ្យយើង មុខយើងប្លែកខុសពី ពីមុនបន្តិច
ដោយសារតែម៉ូតសក់របស់យើងថ្មី។ ដូច្នេះប្រហែលជា សក់របស់គាត់វែងយូរ
ដូច្នេះគាត់ចង់កាត់ដើម្បីប្តូរ ដើម្បីប្តូរម៉ូតសក់ និងដើម្បីឲ្យប្លែកផងដែរ។

បន្ទាប់មកទៀតរូបភាពទី ២ រូបភាពទី ២
ក្រោយពេលដែលគាត់នឹកចង់កាត់សក់របស់គាត់ឲ្យខ្លីត្រឹមក ដើម្បីប្តូរម៉ូតសក់ និងដើម្បីឲ្យប្លែកមុខ
គាត់ក៏បានចេញពីផ្ទះ និងដើរតម្រង់ទៅផ្សារទំនើបដើម្បីរក ដើម្បីរកហាងកាត់សក់។
អញ្ចឹងហាងកាត់សក់នៅកម្ពុជាមានច្រើន ហាងខ្លះគឺពួកគាត់បើកនៅផ្ទះរបស់គាត់
ហាងខ្លះគឺបើកនៅតាមផ្សារទំនើបធំៗ ឬក៏ហាងខ្លះបើកជាហាងធំៗដែលមានការតែងលម្អ
ដោយមានការតុបតែងលម្អយ៉ាងស្រស់ យ៉ាងស្រស់ស្អាត។ អញ្ចឹងទៅតាម ទៅតាមហាង ហាង
ទៅតាមហាង ហាងខ្លះគឺមានតម្លៃថោក ហាងខ្លះគឺមានតម្លៃថ្លៃ អញ្ចឹងអាស្រ័យទៅលើហាង
អាស្រ័យទៅលើហាង ឬក៏ទីតាំង ឬក៏កន្លែងដែលយើងចូលទៅកាត់សក់ ឬក៏ធ្វើសក់នោះ។
អញ្ចឹងគាត់ យើងឃើញគាត់ដើរចូលទៅក្នុងផ្សារទំនើប យើងឃើញគាត់ដើរចូលទៅក្នុងផ្សារទំនើប
ដើម្បីកាត់សក់របស់គាត់ឲ្យខ្លី។

បន្ទាប់មកទៀតរូបភាពទី ៣ រូបភាពទី ៣ គាត់ក៏បានដើរចូលទៅក្នុងផ្សារទំនើប
និងបានមកដល់មុខទ្វារហាងកាត់សក់ ប៉ុន្តែយើងក្រឡេកមើលទៅខាងក្នុងហាងនោះ
យើងឃើញមានភ្ញៀវជាច្រើនអង្គុយ យើងឃើញមានភ្ញៀវជាច្រើនអង្គុយនៅលើកៅអី
កំពុងតែកាត់សក់ កំពុងតែកាត់សក់ អញ្ចឹងយើងឃើញមានជាងម្នាក់
យើងឃើញមានជាងម្នាក់ឈរកាត់សក់ឲ្យភ្ញៀវ ឈរកាត់សក់ឲ្យភ្ញៀវ ឬក៏ធ្វើសក់ឲ្យភ្ញៀវ។
អញ្ចឹងយើងឃើញគាត់ដើរ[ត្រឹម] ដើរចូលក្នុងផ្សារទំនើបមកដល់ខ្លោងទ្វារនៃហាងកាត់សក់នោះ
គាត់ក៏បាន គាត់ក៏បានដើរតម្រង់ ទៅ គាត់ក៏បានដើរតម្រង់ទៅទ្វារ ដើម្បីចូលទៅខាងក្នុង
អញ្ចឹងគាត់ដើរតម្រង់ទៅទ្វារដើម្បី ដើម្បីចូលទៅខាងក្នុង។ បើទោះបីជាមានភ្ញៀវច្រើន
ក៏គាត់អាចអង្គុយរង់ចាំបាន ដោយសារតែគាត់ចង់ប្តូរម៉ូតសក់របស់គាត់
ឬក៏ដោយសារតែថ្ងៃនេះគឺជាថ្ងៃឈប់សម្រាក ដូច្នេះគាត់អាច គាត់អាច គាត់អាចកាត់សក់របស់គាត់
និងអាចរង់ចាំ បើទោះបីជាចំណាយពេលយូរ។ យើងក្រឡេកមើលទៅក្នុងហាង
យើងឃើញមានកញ្ចក់ យើងឃើញមានកញ្ចក់ដាក់សម្រាប់ឲ្យភ្ញៀវ ដាក់សម្រាប់ឲ្យភ្ញៀវឆ្លុះមើល

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

នៅពេលដែលភ្ញៀវតុបតែងមុខ ឬក៏ធ្វើសក់ ឬក៏កាត់សក់រួចរាល់ហើយ ភ្ញៀវអាចមើលដែល ភ្ញៀវអាចមើលកញ្ចក់នោះ ប្រសិនបើត្រង់ណាមិនពេញចិត្ត អាចប្រាប់ជាង ជាងនឹងកែតម្រូវ។ អញ្ចឹងយើងឃើញនៅក្នុងហាងកាត់សក់មួយៗ តែងតែមានកញ្ចក់ មានកៅអីវិល ដើម្បីងាយស្រួលបង្វិល ដើម្បីងាយស្រួលបង្វិល ទៅឆ្វេង ទៅស្តាំ នៅពេលដែលធ្វើសក់ ឬក៏កាត់សក់ និងយើងឃើញជាងនៅទីនោះ គឺជាមនុស្សប្រុស គឺជាមនុស្សប្រុស អញ្ចឹងគាត់បានកាត់ឲ្យភ្ញៀវ។ អញ្ចឹងជាងកាត់សក់ខ្លះគឺជាជាងស្រី ប៉ុន្តែជាងកាត់សក់ខ្លះ គឺជាជាងប្រុស គឺជាជាងប្រុស ប៉ុន្តែពួកគាត់ទាំងពីរគឺកាត់ស្អាតដូចគ្នា គឺកាត់ស្អាតដូចគ្នា។ ប្រហែលជាហាងនៅក្នុងរូបភាពទី ៣ នេះ គឺជាហាងកាត់សក់ដែលកាត់ស្អាត ឬក៏ធ្វើសក់ស្អាត ដូច្នេះយើងឃើញមានភ្ញៀវជាច្រើននៅខាងក្នុង ភ្ញៀវជាច្រើននៅខាងក្នុង និងកំពុងធ្វើការកាត់សក់ និងកំពុងធ្វើការកាត់សក់ ឬក៏ធ្វើសក់។

បន្ទាប់មកទៀត រូបភាពទី ៤ រូបភាពទី ៤ គាត់ក៏ដើរចូលទៅក្នុងហាង ប៉ុន្តែគាត់ នៅពេលដែលគាត់ដើរចូលទៅក្នុងហាង គាត់មិនទាន់កាត់សក់នៅឡើយទេ ដោយ ដោយជាងនៅក្នុងហាងនោះ គាត់តម្រូវ ដោយជាងនៅក្នុងហាងនោះគាត់បានកក់សក់ ឲ្យស្ត្រីម្នាក់នោះជាមុនសិន មុនពេលកក់សក់។ អញ្ចឹងប្រហែលជា ដោយសារតែគាត់ចង់កក់សក់ផង ពីព្រោះពេលខ្លះកក់សក់ដោយខ្លួនឯង គឺ កក់សក់ដោយខ្លួនឯងគឺ ពេលខ្លះគឺខ្ជិល ដោយសារតែពេលខ្លះយើងត្រូវអេះ យើងត្រូវអេះដើម្បីឲ្យសាប៊ូចូល ជ្រាបចូលទៅក្នុងសាច់ក្បាលរបស់យើង ឬក៏យើងត្រូវញី យើងត្រូវញី អញ្ចឹងអ្នកខ្លះនៅពេលដែលកក់សក់ គាត់ខ្ជិល ក្នុងការញី ឬក៏ក្នុងការអេះសក់របស់គាត់ ដើម្បីឲ្យសាប៊ូចូលទៅក្នុងសាច់ក្បាល ឬក៏ពេលខ្លះការកក់សក់ដោយខ្លួនឯងគឺ យើងអត់មានការម៉ាស្សាទេ ប៉ុន្តែការកក់សក់នៅខាងក្រៅគឺមានការម៉ាស្សាក្បាល ដែលធ្វើឲ្យយើង ធ្វើឲ្យយើងមានអារម្មណ៍ថាស្រួលខ្លួន និងបើយើងឈឺក្បាល មានអារម្មណ៍ថា ហាក់បីដូចជាស្រាលក្បាល និងស្រស់ស្រាយ។ អញ្ចឹងយើងឃើញរូបភាពទី ៤ នេះ គាត់បាន គាត់បានទៅ គាត់បានឡើងទៅលើកៅអី បានឡើងទៅលើកៅអី និងទម្រេតខ្លួននៅលើកៅអីនោះ បន្ទាប់មកជាងនៅ ជាងកាត់សក់ នៅក្នុងនោះក៏បានកក់សក់ឲ្យគាត់។ ដោយយើងឃើញដៃម្ខាងរបស់ជាង ដៃខាង យើងឃើញដៃខាងឆ្វេង កាន់ទឹកផ្កាឈូកបាញ់មកលើសក់របស់គាត់ ដៃខាងឆ្វេងគឺកាន់សក់របស់គាត់ ដើម្បីឲ្យទឹកនិងសក់ ឆាប់ ឆាប់ចូលគ្នា។ អញ្ចឹងដើម្បីឲ្យសក់ងាយស្រួល[ទទឹក] ដើម្បីឲ្យសក់ទទឹក ទទឹក និងអាចដាក់សាប៊ូកក់សក់បាន។ អញ្ចឹងយើងឃើញស្ត្រីម្នាក់នោះ យើងឃើញគាត់ដាក់កន្សែង ដាក់កន្សែងនៅលើ ក របស់គាត់ ដោយសារកន្សែងនេះ យើងទុកនៅពេលដែលគាត់កក់សក់ហើយ យើងនឹងយកកន្សែងនោះមករុំសក់របស់គាត់ដើម្បីកុំឲ្យទទឹក។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ពីព្រោះនៅពេលដែលយើងកក់សក់ហើយពេលខ្លះមានទឹកស្រក់ និងធ្វើឲ្យយើង
និងអាចធ្វើឲ្យទទឹកខោអាវ។ ដូច្នេះគាត់ដាក់កន្សែងនៅលើស្មារបស់គាត់
ដើម្បីនៅពេលដែលកក់សក់ហើយ គាត់អាចប្រើកន្សែងនោះ
ដើម្បីប្រើកន្សែងនោះរុំសក់របស់គាត់ដែលទទឹកនោះ អញ្ចឹងយើងឃើញជាងកំពុងតែបាញ់
បាញ់សក់របស់គាត់ដោយប្រើទឹកផ្កាឈូក ដើម្បីឲ្យសក់របស់គាត់ទទឹក ដូច្នេះគាត់អាច
ដូច្នេះជាងអាចប្រើសាប៊ូកក់សក់ ដើម្បីកក់សក់ ដើម្បីកក់សក់ ឬក៏សម្អាតសក់របស់គាត់។

បន្ទាប់មកទៀតរូបភាពទី រូបភាពទី ៥ រូបភាពទី ៥ ក្រោយពេលដែលគាត់បាញ់
ក្រោយពេលដែលគាត់ប្រើទឹកផ្កាឈូកបាញ់សក់របស់ស្ត្រីម្នាក់នោះឲ្យទទឹកល្មមនិង ឲ្យទទឹកល្មម
និងអាចដាក់សាប៊ូបាន អញ្ចឹងបន្ទាប់មកជាងក៏បាន ជាងក៏បានយកសាប៊ូកក់សក់មក មកដាក់
មកច្របាច់លើក្បាលរបស់ស្ត្រីម្នាក់នោះ ដើម្បីធ្វើការកក់សក់ឲ្យគាត់។
អញ្ចឹងយើងឃើញជាងកំពុងតែញី ញីក្បាលរបស់គាត់
ឬកំពុងតែអេះក្បាលរបស់គាត់ដើម្បីឲ្យពពុះសាប៊ូ ជ្រាបចូលទៅក្នុងសាច់ក្បាលដើម្បី
ដើម្បីកម្ចាត់មេរោគដែលមានជាប់នៅសាច់ក្បាលនោះ។ អញ្ចឹង ក្បាលក៏ ពេលខ្លះក៏មានមេរោគ
និងធូលីដីដែរ មានន័យថានៅពេលដែលយើងដើរ ដើរនៅតាមផ្លូវ ពេលខ្លះធូលីដីដែលហើរ គឺ
ពេលខ្លះធូលីដីដែលហើរ ពេលខ្លះអាចប៉ះនឹងសក់របស់យើង និងប្រសិនបើយើងអត់បានកក់សក់
និងសម្អាតសក់របស់យើងឲ្យស្អាតទេ ស្បែកក្បាលនឹងអាចមានបញ្ហា ដូចជាមានបញ្ហារមាស់
មានបញ្ហារមាស់
ឬក៏ពេលខ្លះអាចមានបញ្ហាដំបៅនៅលើសាច់ក្បាលរបស់យើងដោយសារតែមានចៃ។
អញ្ចឹងអ្នកខ្លះដែល អ្នកខ្លះដែលអត់បានកក់សក់ អ្នកខ្លះដែលអត់បានកក់សក់ ជាក់ស្តែងដូចជា
អ្នកដែលរស់នៅតាមជនបទ ពេលខ្លះនៅតំបន់មួយចំនួនគាត់អត់មានទឹកទេ
និងពេលខ្លះនៅតំបន់គាត់គឺក្រីក្រ មានន័យថាពួកគាត់មិនសូវមានលុយ
ដូច្នេះពួកគាត់មិនមានសាប៊ូកក់សក់ និងក៏មិនសូវមានទឹកដែរ
ដូច្នេះពួកគាត់នៅពេលដែលមុជទឹកត្រូវសន្សំសំចៃ។ ដូច្នេះក្បាលរបស់គាត់គឺមានចៃ។
ចៃគឺជាសត្វល្អិតម្យ៉ាងដែលទំនៅលើស្បែកក្បាលរបស់យើង ដែលកើតចេញពីក្អែល ឬក៏ស្បែក
កើតចេញពីមេរោគ ដែលតោងជាប់ទៅនឹងស្បែកក្បាលរបស់យើង។ អញ្ចឹងនៅពេលដែលមានចៃ
ចៃនោះនឹងខាំក្បាលរបស់យើង បង្កើតឲ្យមានដំបៅ។ អញ្ចឹងការសម្អាតក្បាល ការកក់សក់
គឺសំខាន់។ អញ្ចឹងគាត់បានចូលមកហាង គាត់ចូលបាន គាត់ចូលមកហាងកាត់សក់
មុនពេលកាត់សក់គាត់ត្រូវកក់សម្អាត កក់សម្អាតសក់របស់គាត់ និងសម្អាតសាច់ សាច់ក្បាល
ស្បែកនូវ និងសម្អាត និងសម្អាតស្បែកក្បាលរបស់គាត់ជាមុនសិន ដើម្បី
ដើម្បីឲ្យមានអារម្មណ៍ស្រស់ស្រាយ ដើម្បីឲ្យមានអារម្មណ៍ស្រស់ស្រាយ និងកុំឲ្យរមាស់ផងដែរ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងយើងឃើញជាងកាត់សក់កំពុងតែអេះក្បាលរបស់គាត់
ដោយយើងឃើញមានពពុះសាប៊ូជាច្រើន យើងឃើញមានពពុះសាប៊ូជាច្រើន។
នៅក្បែរនោះយើងឃើញមានដបសាប៊ូពីរ ប្រើសម្រាប់កក់ឲ្យភ្ញៀវ។
អញ្ចឹងនៅហាងកាត់សក់មានសាប៊ូច្រើនប្រភេទ
យើងអាចជ្រើសរើសទៅតាមសាប៊ូណាដែលយើងពេញចិត្ត។

បន្ទាប់មកទៀតរូបភាពទី រូបភាពទី ៦ រូបភាពទី ៦
ក្រោយពេលកក់សម្អាតសក់របស់ស្ត្រីម្នាក់នោះបានស្អាតហើយ ជាងក៏បាន
ជាងក៏បានលើកយកទឹកផ្កាឈូកមកបាញ់ដើម្បីសម្អាតសាប៊ូនោះ[ចេញ]
ដើម្បីសម្អាតសាប៊ូនោះឲ្យស្អាត។ អញ្ចឹងយើងឃើញជាងធ្វើដោយយកចិត្តទុកដាក់
ពីព្រោះមិនចង់ឲ្យទឹកចូលទៅក្នុងភ្នែក ឬក៏មិនចង់ឲ្យសាប៊ូចូលទៅក្នុងភ្នែករបស់ភ្ញៀវ។
ដូច្នេះពួកគាត់ត្រូវកក់សម្អាតសក់ ដោយយកចិត្តទុកដាក់ ដើម្បីឲ្យភ្ញៀវពេញចិត្ត។
អញ្ចឹងយើងឃើញគាត់បានប្រើទឹកផ្កាឈូក បាញ់លាងសម្អាតសាប៊ូឲ្យស្ត្រីម្នាក់នោះ។

បន្ទាប់មកទៀតរូបភាពទី ៧ រូបភាពទី ៧ ក្រោយពេលដែលគាត់កក់សក់ និងសម្អាតសក់ស្អាតហើយ
ស្ត្រីម្នាក់នោះគាត់ក៏ដើរមកអង្គុយនៅលើកៅអី មកលើកៅអីវិលដើម្បីធ្វើការកាត់សក់។
អញ្ចឹងដោយសារតែដំបូងសក់របស់គាត់ទទឹក អញ្ចឹងគាត់ជូតសម្អាតសក់របស់គាត់
និងផ្លុំសក់របស់គាត់ស្ងួតហើយ គាត់ក៏ គាត់ក៏ដើរមក គាត់ក៏
គាត់ក៏ប្រាប់ជាងអំពីម៉ូតសក់ដែលគាត់ចង់កាត់។ អញ្ចឹងយើងឃើញគាត់អង្គុយនៅលើកៅអីវិល
និងគាត់កាន់កន្សែង គាត់កាន់កន្សែងដែលដាក់ជាប់នៅលើស្មារបស់គាត់យ៉ាងជាប់
និងនៅខាងមុខគាត់យើងឃើញមានកញ្ចក់ យើងឃើញមានកញ្ចក់ប្រើសម្រាប់ឆ្លុះមុខ
និងប្រដាប់ប្រដាផ្សេងៗទៀត ដែលមានដូចជាក្រាសសិតសក់ ឬក៏តង្កៀប
ឬក៏ជាកៅស៊ូដែលដាក់នៅខាងមុខនោះ។ អញ្ចឹងយើងឃើញជាង ជាងកាត់សក់ដែលជាមនុស្សប្រុស
ដែលជាជាងប្រុស យើងឃើញជាងកាត់សក់ គឺពាក់ឯកសណ្ឋាន
ពាក់ឯកសណ្ឋានជាជាងកាត់សក់នៅក្នុងហាង ដោយយើងឃើញគាត់ពាក់អាវពណ៌សដៃ
គាត់ពាក់អាវសដៃវែង ប៉ុន្តែគាត់មូរដៃរបស់គាត់ មូរដៃអាវរបស់គាត់ឡើងទៅលើ
និងគាត់ស្លៀកខោជើងវែងពណ៌ស។ នៅក្នុងដៃរបស់គាត់មានសៀវភៅម៉ូតសក់
ពីព្រោះពេលខ្លះគាត់មិនអាចកាត់សក់តម្រូវចិត្តរបស់
គាត់មិនអាចកាត់សក់ដោយគ្មានការកុម្ម៉ង់ពីភ្ញៀវបានទេ ពីព្រោះពេលខ្លះគាត់ចូលចិត្តម៉ូតនេះ
ប៉ុន្តែភ្ញៀវគាត់ចូលចិត្តម៉ូតនោះ។ ដូច្នេះគាត់ត្រូវមានសៀវភៅមួយក្បាល
សម្រាប់ឲ្យភ្ញៀវជ្រើសរើសនូវម៉ូតសក់ដែលគាត់ចង់កាត់ ដូច្នេះជាងអាច

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដូច្នេះជាងកាត់សក់អាចកាត់ទៅតាមនោះ និងអាច និង និងភ្ញៀវក៏ពេញចិត្តផងដែរ
និងមិនចំណាយពេលយូរ។ អញ្ចឹងជាងកាត់សក់ក៏បានយកសៀវភៅដើម្បីហុចឲ្យស្ត្រីម្នាក់នោះ
ធ្វើការជ្រើសរើស។ នៅក្បែរជើងរបស់ស្ត្រីម្នាក់នោះ នៅខាងក្រោមទូ
ដែលមានកញ្ចក់នៅជាប់នឹងជញ្ជាំង នៅខាងក្រោមនោះយើងឃើញមានធុងសំរាមមួយ
ដែលធុងសំរាមនោះយើងទុកនៅទីនោះ សម្រាប់នៅពេលដែលគាត់មាន នៅពេលដែលគាត់
នៅពេលដែលគាត់មានសំរាម មានសំរាម នៅពេលដែលគាត់មានសំរាម
គាត់អាចបោះចូលទៅក្នុងនោះ។ នៅពេលខ្លះគាត់អាចប្រើក្រដាសជូតមាត់ ឬក៏ពេលខ្លះគាត់អាចញ៉ាំ
ញ៉ាំអីនៅអំឡុងពេលកាត់សក់ ដូចជាពេលខ្លះគាត់អាចញ៉ាំស្ករគ្រាប់ដើម្បីកុំឲ្យអផ្សុក
អញ្ចឹងគាត់អាចបោះសំបកនោះចូលទៅក្នុងធុងសំរាមនោះបាន។
ឬក៏ពេលខ្លះនៅពេលដែលជាងកាត់សក់ឲ្យភ្ញៀវហើយ
ជាងនឹងប្រមូលសក់របស់ភ្ញៀវដាក់ចូលទៅក្នុងធុងសំរាមនោះ។

បន្ទាប់មកទៀតរូបភាពទី ៨ រូបភាពទី ៨ រូបភាពទី ៨ ជាងក៏បាន ជាងក៏បានហុចសៀវភៅ
ហុចសៀវភៅម៉ូតសក់នោះឲ្យទៅស្ត្រីម្នាក់នោះ។ ស្ត្រីម្នាក់នោះគាត់ចង់កាត់សក់របស់គាត់ឲ្យខ្លី
ដូច្នេះគាត់ក៏បានឃើញម៉ូតសក់នៅក្នុង នៅក្នុងសៀវភៅដូចអ្វីដែលគាត់ចង់ធ្វើ ដូច្នេះគាត់ក៏
ដូច្នេះគាត់ក៏ចង្អុលបង្ហាញ ទៅកាន់រូបភាពដែលមានសក់ខ្លីត្រឹមក ដើម្បីប្រាប់ជាង
ឲ្យជាងកាត់សក់ម៉ូតនោះឲ្យគាត់។

បន្ទាប់មកទៀតរូបភាពទី ៩ រូបភាពទី ៩
ក្រោយពេលដែលស្ត្រីម្នាក់នោះប្រាប់អំពីម៉ូតសក់របស់គាត់ទៅជាង ជាងក៏បាន
ជាងក៏បានយកក្រណាត់ ជាងក៏បានយកក្រណាត់ មករុំ មករុំនៅលើ ក របស់គាត់
ដើម្បីបាំងខ្លួនរបស់គាត់ កុំឲ្យនៅពេលដែលគាត់ កុំឲ្យនៅពេលដែលជាងកាត់សក់
កម្ទេចសក់នោះអាចចូលទៅក្នុង អាចចូលទៅប៉ះនឹងខ្លួន ដូច្នេះអាចធ្វើឲ្យគាត់ស្មៀបបាន។
អញ្ចឹងមុនពេលកាត់សក់ ជាងត្រូវប្រើក្រណាត់ដើម្បីរុំគ្រប ដើម្បី ដើម្បីគ្របខ្លួន ឬក៏ គ្របនៅជុំវិញ
ជុំវិញក ជុំវិញខ្លួន ដើម្បីកុំឲ្យកម្ទេចរបស់សក់តូចៗដែលបានកាត់នោះ ប៉ះទៅនឹងក
ឬក៏ប៉ះទៅនឹងខ្លួន ពីព្រោះអាចធ្វើឲ្យស្មៀប និងរមាស់បាន។
អញ្ចឹងយើងឃើញគាត់បានយកមកពាក់នៅជុំវិញករបស់ស្ត្រីម្នាក់នោះ។

បន្ទាប់មកទៀតរូបភាពទី ១០ រូបភាពទី ១០ ជាងក៏បានយកកន្ត្រៃនិងក្រាសសិតសក់
យកមកកាត់សក់ស្ត្រីម្នាក់នោះឲ្យខ្លីទៅតាមម៉ូតសក់ដែលគាត់ចង់បាន។ អញ្ចឹងយើងឃើញជាង
ដៃម្ខាងកាន់កន្ត្រៃ ដៃខាងស្តាំកាន់កន្ត្រៃ ដៃខាងឆ្វេងគឺកាន់ក្រាសសិតសក់។ អញ្ចឹងគាត់កាត់បណ្តើរ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់សិតបណ្ដើរ ដើម្បីឲ្យច្បាស់ថាសក់ដែលគាត់កាត់នោះ គឺស្មើល្អ
ពីព្រោះពេលខ្លះប្រសិនបើយើងមិនបានសិតមើលទេ ពេលខ្លះយើងអាច
នៅពេលដែលកាត់សក់ម្ខាងវែងម្ខាងខ្លី អញ្ចឹងគាត់ត្រូវកាត់បណ្ដើរ សិតបណ្ដើរ
ដើម្បីឲ្យច្បាស់ថាសក់របស់គាត់គឺស្មើ គឺស្មើនិងស្អាត។ អញ្ចឹងជាងគាត់មានជំនាញខាងកាត់សក់
អញ្ចឹងយើងឃើញជាងគាត់មានជំនាញខាងកាត់សក់ គឺយើងឃើញគាត់កាត់សក់លឿន
យើងឃើញគាត់កាន់ កាត់ កាត់សក់លឿន និងកាន់កន្ត្រៃកាត់សក់របស់ស្ត្រីម្នាក់នោះ
ដោយមិនមានការព្រួយបារម្ភ ដោយមិនមានការព្រួយបារម្ភខ្លាចខូចម៉ូតសក់
ឬក៏មិនមានការព្រួយបារម្ភខ្លាចកាត់សក់ខុស ដោយសារតែគាត់គឺជាជាងកាត់សក់យូរឆ្នាំមកហើយ។

បន្ទាប់មកទៀតរូបភាពទី ១១ រូបភាពទី ១១ ក្រោយពេលដែល
ក្រោយពេលដែលជាងកាត់សក់ឲ្យស្ត្រីម្នាក់នោះរួចរាល់ហើយ ជាងក៏បានយក
ជាងក៏បានយកប្រដាប់ផ្លុំសក់មកផ្លុំសក់ឲ្យគាត់ ពីព្រោះនៅពេលដែលគាត់កក់សក់
គឺសក់របស់គាត់មិនទាន់ស្ងួតនៅឡើយទេ បើទោះបីមានការជូតសម្អាត ឬក៏ផ្លុំលើកដំបូងក៏ដោយ
ប៉ុន្តែមិនទាន់ស្ងួត មិនទាន់ស្ងួត មិនទាន់ស្ងួតល្អនៅឡើយទេ។ ដូច្នេះនៅពេលដែល
នៅពេលជាងកាត់សក់ឲ្យស្ត្រីម្នាក់នោះរួចរាល់ហើយ ជាងក៏បានយកម៉ូតសក់មកផ្លុំ យកប្រដាប់ផ្លុំសក់
យកប្រដាប់ផ្លុំសក់មកផ្លុំសក់ឲ្យស្ត្រីម្នាក់នោះ ដើម្បីឲ្យសក់របស់គាត់
ដើម្បីឲ្យសក់របស់គាត់មើលទៅឃើញស្អាត។

បន្ទាប់មកទៀតរូបភាពទី ១២ រូបភាពទី១២ ក្រោយពេលផ្លុំសក់រួចរាល់ហើយ ជាងក៏បានយក
ជាងក៏បានយកស្ព្រៃយ៍បាញ់សក់ ដើម្បីបាញ់នៅលើសក់របស់ស្ត្រីម្នាក់នោះ
ដើម្បីឲ្យសក់មើលទៅស្អាត មើលទៅស្អាត និងទន់រលោង និងចង់ឲ្យសក់រាប រាបស្មើ
ដើម្បីមើលទៅឲ្យឃើញស្អាត រាបស្មើដើម្បីឲ្យសក់មើលទៅឃើញស្អាត
អញ្ចឹងជាងកាន់ស្ព្រៃយ៍បាញ់សក់នៅក្នុងដៃរបស់គាត់ គាត់កាន់បណ្ដើរ គាត់ គាត់កាន់បណ្ដើរ
គាត់ដៃម្ខាងទៀត គឺគាត់ផ្ចិតផ្ចង់ ដៃម្ខាងទៀតរៀបចំ
ឬក៏តុបតែងម៉ូតសក់របស់គាត់ដើម្បីឲ្យមើលទៅស្អាត
ក្រោយពេលដែលគាត់បាញ់ស្ព្រៃយ៍បាញ់សក់នោះហើយ។

បន្ទាប់មកទៀតរូបភាពទី រូបភាពទី ១៣
ក្រោយពេលដែលជាងបាញ់ស្ព្រៃយ៍បាញ់សក់ទៅលើសក់របស់ស្ត្រីម្នាក់នោះរួចរាល់ហើយ
ជាងក៏បានយកកញ្ចក់មួយទៀតដើម្បី ដើម្បីដាក់ពីក្រោយស្ត្រីម្នាក់នោះ
ដើម្បីឲ្យគាត់បានមើលឃើញសក់របស់គាត់ខាងក្រោយ។ ពីព្រោះពេលខ្លះ ពេលខ្លះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បើទោះបីជាមានកញ្ចក់នៅខាងមុខ នៅពេលដែលគាត់មើល
ពេលខ្លះគាត់មើលបានឃើញទៅត្រឹមខាងមុខ អញ្ចឹងខាងក្រោយគាត់អត់ដឹងថាស្អាត ឬក៏មិនស្អាត
ឬក៏ពេញចិត្តគាត់ដែរឬទេ ដូច្នេះនៅពេលដែល នៅពេលដែលជាងកាត់សក់ហើយ
ជាងតែងតែយកកញ្ចក់មួយទៀត យកមកដាក់នៅខាងក្រោយ
ដើម្បីងាយស្រួលឲ្យភ្ញៀវគាត់បានមើលនូវសក់ខាងក្រោយរបស់គាត់
ពីព្រោះប្រសិនបើពេលខ្លះភ្ញៀវអត់ពេញចិត្ត ជាងនឹងអាចសារ៉េកែតម្រូវសក់នោះ ដើម្បីឲ្យស្អាត
ដើម្បីឲ្យស្អាត និងដើម្បីឲ្យភ្ញៀវពេញចិត្ត។ អញ្ចឹងប្រសិនបើ ប្រសិនបើភ្ញៀវមើលទៅពេញចិត្តហើយ
ដូច្នេះជាងមិនបាច់ មិនចាំបាច់ សារ៉េសក់នោះបន្ថែមទៀតទេ។ អញ្ចឹងយើងឃើញ អញ្ចឹងយើងឃើញ
យើងឃើញជាងកាត់សក់កាន់កញ្ចក់នៅក្នុងដៃរបស់គាត់ទាំងពីរ
ស្ត្រីម្នាក់នោះក្រោយពេលដែលជាងកាត់សក់ និងផ្លុំសក់
និងបាញ់ប្រេងស្ព្រៃយ៍នៅលើសក់របស់គាត់មើលទៅស្អាតហើយ យើងឃើញមើលទៅស្អាតហើយ
គាត់ក៏បានសម្លឹងមើលទៅខាងក្រោយទៀត ដើម្បីឲ្យ ឲ្យច្បាស់ថានៅខាងក្រោយ
ក៏គាត់ពេញចិត្តដែរ។

បន្ទាប់មកទៀតរូបភាពទី ១៤ រូបភាពទី ១៤ ក្រោយពេលដែលគាត់មើលខាងមុខ
មើលខាងក្រោយហើយ គាត់ពេញចិត្តនឹងម៉ូតសក់ថ្មីនេះណាស់
យើងឃើញម៉ូតសក់របស់គាត់គឺកាត់ខ្លីត្រឹមក អញ្ចឹងយើងឃើញមើលទៅគាត់ស្អាត និងប្លែក
គាត់ស្អាត និងមើលទៅប្លែកមុខ និងមើលទៅប្លែកមុខ
ដោយសារតែពីមុនយើងឃើញសក់របស់គាត់គឺវែង ប៉ុន្តែឥឡូវនេះគាត់កាត់សក់ខ្លី
យើងមើលទៅឃើញប្លែក។ អញ្ចឹងយើងឃើញម៉ូតសក់ដែលជាងកាត់ឲ្យ
គឺធ្វើឲ្យគាត់ពេញចិត្តខ្លាំងណាស់ ពីព្រោះម៉ូតសក់នេះគឺជា គឺជាម៉ូតសក់ដែលគាត់ចង់បាន
គឺជាម៉ូតសក់ដែលគាត់ចង់បាន។ អញ្ចឹងជាងក៏សប្បាយចិត្តដែរ
នៅពេលដែលភ្ញៀវពេញចិត្តនឹងម៉ូតសក់នោះ។

បន្ទាប់មកទៀតរូបភាពទី ១៥ រូបភាពទី ១៥ ក្រោយពេលដែលភ្ញៀវពេញចិត្តហើយ
ដែលស្ត្រីម្នាក់នោះពេញចិត្តនឹងម៉ូតសក់របស់គាត់ហើយ
ជាងកាត់សក់ក៏បានយកច្រាសមកបោសសម្អាត
យកច្រាសមកបោសសម្អាតនៅលើកន្សែងដែលរុំនៅលើ ក របស់គាត់ ដើម្បីឲ្យកម្ទេចសក់ល្អិតៗ
ចេញទៅ ធ្លាក់ចុះទៅដី ពីព្រោះប្រសិនបើកម្ទេចសក់នោះតោងជាប់នឹងស្បែករបស់គាត់
ពេលខ្លះអាចធ្វើឲ្យគាត់រមាស់ និងស្ញៀប ពេលខ្លះអាចធ្វើឲ្យគាត់រមាស់ និងស្ញៀប ដូច្នេះ
នៅពេលដែលកាត់សក់ហើយ ជាងតែងតែបោសសម្អាត បោសសម្អាត

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដើម្បីកុំឲ្យកម្ទេចសក់នោះជាប់នឹងស្បែក ឬក៏ជាប់នឹងខ្លួនរបស់ភ្ញៀវ។ អញ្ចឹងយើងឃើញជាងកាត់សក់ ដៃម្ខាងគឺកាន់ច្រាស ដៃម្ខាង ដៃម្ខាងកាន់ច្រាស ដៃម្ខាងទៀតកាន់កៅអី ដើម្បីងាយស្រួលបង្វិលកៅអីទៅឆ្វេងទៅស្ដាំ ពីព្រោះ ពីព្រោះកៅអីនេះគឺជាកៅអីវិល ដូច្នេះ នៅពេលដែលគាត់ចង់ងាកឆ្វេង ងាក ពីព្រោះនៅពេលដែលគាត់ចង់បង្វិលឆ្វេង បង្វិលស្ដាំ គាត់មិនចាំបាច់ប្រាប់ឲ្យស្ត្រីម្នាក់នោះងាកខ្លួនទេ ដោយគាត់គ្រាន់តែបង្វិលកៅអីនោះ។ អញ្ចឹងដៃម្ខាងគាត់កាន់កៅអីដើម្បីបង្វិល ដៃម្ខាងទៀតគឺគាត់កាន់ច្រាស ដើម្បីបោសកម្ទេចសក់នោះទៅលើដី ឲ្យធ្លាក់ទៅលើដី។

បន្ទាប់មកទៀតរូបភាពទី ១៦ រូបភាពទី ១៦ ជាងក៏បានយកក្រណាត់ដែលរុំនៅលើ ក របស់គាត់នោះចេញ រុំនៅលើ ក របស់ របស់គាត់នោះចេញ ដោយគាត់បែរកៅអី នៅពេលដែលគាត់ នៅពេលដែលជាងបានយកក្រណាត់ ក្រណាត់រុំកនៅលើ ក របស់ស្ត្រីម្នាក់នោះយកចេញ ស្ត្រីម្នាក់នោះក៏បានបែរ បែរមកនិយាយជាមួយជាង ដើម្បីសួរតម្លៃ ពីព្រោះថ្ងៃនេះគាត់បានកក់ គាត់បានកាត់សក់ផង គាត់កក់សក់ផង ដូច្នេះគាត់ចង់ដឹងអំពីតម្លៃតើអស់ប៉ុន្មាន ដូច្នេះ មុនពេលដែលគាត់ទៅផ្ទះ គាត់ត្រូវឲ្យលុយទៅជាងសិន។ អញ្ចឹងនៅពេលដែល នៅពេលដែលគាត់សួរតម្លៃ ជាងក៏បានប្រាប់តម្លៃ ទៅស្ត្រីម្នាក់នោះថាអស់ប្រាំដុល្លារ ដូច្នេះស្ត្រីម្នាក់នោះក៏បានហុចលុយឲ្យជាង បន្ទាប់មកគាត់ក៏បានដើរត្រលប់ទៅផ្ទះ។ អញ្ចឹងនៅហាងនេះ គឺការកក់សក់ និងកាត់សក់ គឺអត់ថ្លៃទេ អស់ត្រឹមតែប្រាំដុល្លារតែប៉ុណ្ណោះ គាត់អាចកាត់សក់ផង គាត់អាចកក់សក់ផង។ អញ្ចឹងតម្លៃថ្លៃឬថោកគឺអាស្រ័យទៅលើហាង។ ហាងខ្លះតូចគឺតម្លៃថោក ហាងខ្លះធំមានការតុបតែងលម្អមើលទៅស្អាត គឺមានតម្លៃថ្លៃ។ អញ្ចឹងតម្លៃថោកឬថ្លៃគឺអាស្រ័យទៅលើហាង។ ដូច្នេះស្ត្រីម្នាក់នោះ ក្រោយពេលដែលកាត់សក់រួចរាល់ហើយ គាត់ក៏បានឲ្យលុយទៅជាង គាត់ក៏បានឲ្យលុយ[ឲ្យ]ទៅជាង ប្រាំដុល្លារ បន្ទាប់មកគាត់ក៏បានដើរត្រលប់ទៅផ្ទះវិញ ដោយសប្បាយចិត្ត ជាមួយនឹងទឹកមុខយ៉ាងសប្បាយចិត្ត ដោយសារតែគាត់បាន ដោយសារតែគាត់ថ្ងៃនេះ បានកាត់សក់ឲ្យខ្លីទៅតាមអ្វីដែលគាត់ចង់ ទៅតាមអ្វីដែលគាត់ ដែលគាត់ចង់បាន។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.